# ការសម្ភាសរបស់ ពៅ យ៉ាន

ក. អ្នកសម្ភាស ជាង ស៊ីអ៊ាវ ខ. ពៅយ៉ាន

កៈ ដោយសារតែថ្ងៃហ្នឹងថ្ងៃទី៩ខែមិនាឆ្នាំ២០១៦ អញ្ចឹងខ្ញុំឈ្មោះជានស៊ីអ៊ាវហើយខ្ញុំមានការសម្ភាសលោកយាយបន្តិច លោកយាយឈ្មោះពេញលោកយាយឈ្មោះអ្វីដែរ?

ខៈ ឈ្មោះ ពៅ យ៉ាន

កៈ ពៅ យ៉ាន

ខៈ ចាស៎

កៈ ចុះលោកយាយមានដឹងថ្ងៃខែឆ្នាំកំណើតលោកយាយទេ?

ខៈ ខ្ញុំដឹងឆ្នាំ ឆ្នាំខ្ញុំកើតនៅ១៩៥៣

កៈ ១៩៥៣

ខៈ ចាស៎

កៈ យាយឥឡូវហ្នឹងអាយុប្រហែលប៉ុន្មានហើយ?

ខៈ ឥឡូវហ្នឹង៧៣ហើយ

កៈ ៧៣ហើយ

ខៈ ចាស៎!

កៈ ចុះលោកយាយកើតនៅណាវិញទៅ?

ខៈ ខ្ញុំកើតនៅភូមិព្រៃកតាអី ឃុំព្រៃកតាអី ភូមិព្រៃកតាអីដែរ។

កៈ ខេត្ត?...

ខៈ ខេត្ត... ស្រុករំដួល ខេត្តស្វាយរៀង

កៈ ខេត្តស្វាយរៀង

ខៈ ចាស៎!

កៈ ចុះសម្រាប់លោកយាយមានកូនប៉ុន្មាននាក់ដែរ?

ខៈ ខ្ញុំកូន៣នាក់

កៈ កូនលោកយាយឈ្មោះអីខ្លះ?

ខ៖ ឈ្មោះ អ្នក វង ចាន់នី... វង ស៊ីណាត់... ហើយនិង វងឡូច

ក៖ អរគុណដែរ។ ចុះពួកគាត់កើតនៅភូមិឃុំជាមួយគ្នា...?

ខ៖ ដូចគ្នា ចាស៎ ដូចគ្នា

ក៖ ចុះសម្រាប់ប្តីលោកយាយឈ្មោះអីដែរ?

ខ៖ ប្តីខ្ញុំ វង សន

ក៖ ចុះគាត់ធ្វើអីគេវិញលោកយាយ?

ខ៖ គាត់ធ្វើទាហានកាល លន់ នល់

ក៖ គាត់កាលលន់នល់ គាត់ធ្វើទាហាន

ខ៖ ចាស៎

ក៖ ចុះឥឡូវគាត់...?

ខ៖ គាត់ស្លាប់យូរហើយតាំងពី '៧៥

ក៖ ហេតុអីគាត់ស្លាប់លោកយាយ?

ខ៖ ខ្ញុំមិនដឹងដែរ ត្រូវគ្រាប់ហ្នឹងអីហ្នឹង
គាត់ធ្វើទាហានបាត់ឈ្មោះបោះសម្លេងតាំងពីថ្ងៃនោះមកឆ្នាំហ្នឹងមក

ក៖ បាទលោកយាយ។ ចុះលោកយាយសម្រាប់ការពិនិត្យតូច
លោកយាយដូចជាបានរៀនសូត្រទេលោកយាយ?

ខ៖ ខ្ញុំបានរៀនចាប់ពីដើម គេហៅថ្នាក់កុមារដ្ឋាន បរិវចនដ្ឋាន អធិការដ្ឋាន ត្រឹមហ្នឹង ចាស៎ ត្រឹមហ្នឹង

ក៖ ថ្នាក់កុមារដ្ឋាន វចនដ្ឋាន ហើយនិងបរិវចនដ្ឋាន ថ្នាក់ដូចជារៀនម៉េចវិញលោកយាយចាំទេ?

ខ៖ ថ្នាក់ហ្នឹងរៀនដូចឥឡូវហ្នឹង ទី១ ទី២ ទី៣ ប៉ុនជំនាន់ហ្នឹងគេមិនហៅអញ្ចឹងទេ! ចាស៎
គេហៅកុមារដ្ឋាន បរិវចនដ្ឋាន អធិការដ្ឋាន ចាស៎។

ក៖ កាលហ្នឹងដូចជានៅសម័យបារាំង?... មកពីសម័យអីគេលោកយាយ?

ខ៖ សម័យតាសីហនុមុន។

ក៖ ហើយប្រហែលជាឆ្នាំណាវិញ លោកយាយចាំទេ?

ខ៖ ខ្ញុំចូលរៀនហ្នឹងប្រហែលជាឆ្នាំ '៦៨ '៦៩

ក៖ ចុះសម្រាប់លោកយាយរៀនហ្នឹងមានបញ្ហាអីកើតឡើងសម្រាប់ជីវិតលោកយាយ?

ខ៖ ខ្ញុំក្រណាស់ ដល់ខ្ញុំឡើងទៅថ្នាក់ទៀតខ្ញុំឥតមានកង់ជិះ ចាស៎ អត់មានកង់ជិះទេ

ហើយខ្ញុំក៏ឈប់រៀន លោកគ្រូគាត់ស្តាយខ្ញុំណាស់ ចុះរៀនភូមិព្រែកតាអីហ្នឹងហើយ ទៅពីសោមវាឆ្ងាយហើយសុទ្ធតែព្រៃៗ ហើយ ឪពុកម៉ែខ្ញុំអត់អោយទៅទេ ខ្លាចណាស់ យើងដើរខ្លាច ហើយក៏ខ្ញុំឈប់ត្រឹមហ្នឹងទៅ

ក៖ ហើយចុះសម្រាប់សាលាឆ្ងាយទេ?

ខ៖ ឆ្ងាយណាស់សាលា។

ក៖ ប្រហែលជាប៉ុន្មានគីឡូទៅ?

ខ៖ បីបួនប្រាំគីឡូនៅស្រុកសុទ្ធតែព្រៃកាលនោះ ចាស៎ តាមថ្នល់សុទ្ធតែព្រៃ។

ក៖ ចុះអ្នករៀនច្រើនអត់?

ខ៖ អ្នករៀនហ្នឹងតិចដែរ។

ក៖ មួយថ្នាក់ប៉ុន្មាននាក់ទៅ?

ខ៖ មួយថ្នាក់៣០នាក់ ជាង២០នាក់ ចាស់ជំនាន់ហ្នឹង។

ក៖ ប៉ុន្តែរៀនហ្នឹងដូចជាលោកយាយ រៀនហ្នឹងដូចជារៀនចេះដែរទេលោកយាយ?

ខ៖ ខ្ញុំអានកាលហ្នឹងអាចចេះ ចេះតែជាប់ ចេះតែឡើង ដល់ឡើងថ្នាក់ទៅថ្នាក់ស្រុកគេ ខ្ញុំលែងបានទៅ ព្រោះគ្រូអោយជាប់ទៅទៀត វាក្រពេក វាគ្មានស្អីណាជិះ ហើយម្យ៉ាងទៀតក្នុងជំនាន់ហ្នឹងស្រីៗពុកម៉ែមិនបណ្តោយណា ចាស៎។

ក៖ បាទលោកយាយ។ ចុះរហូតបន្ទាប់ពីលោកយាយឈប់រៀនលោកយាយធ្វើអីគេវិញទៅ?

ខ៖ ខ្ញុំធ្វើស្រែ ធ្វើស្រែអាយុដល់ខ្ញុំ...ឆ្នាំ៦០...ឆ្នាំ '៦៩ខ្ញុំរៀបការ ចាស់។

ក៖ ចុះលោកយាយរៀបការឆ្នាំ '៦៩

ខ៖ ចាស៎ ឆ្នាំ '៦៩

ក៖ ចុះនៅពេលដែលលោកយាយរៀបការហើយ ប្តីលោកយាយចាប់ផ្តើមធ្វើអីគេវិញទៅ?

ខ៖ អត់ទេកាលហ្នឹងមិនទាន់ចាប់ផ្តើមទេ នៅធ្វើស្រែទាំងអស់គ្នា ចាស៎ ហើយខ្ញុំក៏បានកូនមួយ កូនពីរ កូនបីហ្នឹងជួបមុខពុកតែម្តងទេ ហើយខ្ញុំក៏មានផ្ទៃពោះកូនចុងក្រោយ ចាស៎ គាត់ទៅធ្វើទាហាន ហ្នឹងហើយ ចាស

ក៖ បាទ ដូចជានៅពេលដែល ដូចជាជំនាន់ ប៉ុល ពត ដំបូងហ្នឹងចូលមកហ្នឹង លោកយាយមានបញ្ហាអីកើតឡើង?

ខ៖ អ៎ូ ខ្ញុំវេទនាណាស់ គ្រាប់ប្លោងព្រោះខ្ញុំនៅជាយដែន គ្រាប់ប្លោងទាំងយប់ទាំងថ្ងៃ ពេលថ្ងៃម៉ោង៣ម៉ោង៤អញ្ចឹង នាំកូនទៅអន្លង់ត្រង់សេដើម្បីចាំមាត់នៅមាត់អន្លង់ហ្នឹង តែឮភើងអីកើត ព្រយចូលក្នុងអន្លង់ត្រង់សេ ដូចកណ្តុរអញ្ចឹង ត្រៀមតែបាយហូប ពេលណាស្ងាតចេញដាំបាយអោយកូនហូប ហូបហើយអង្គុយលើគុនិងមាត់ «5:13 »

កៈ អុំ នៅពេលហ្នឹងគេលោកយាយធ្វើអីគេទៅ?

ខៈ ខ្ញុំនៅមើលកូនហ្នឹង មើលកូន

កៈ យាយមើលកូន។ ចុះប្តីលោកយាយធ្វើអី?

ខៈ ប្តីទៅធ្វើទាហានហ្នឹង

កៈ អុំ ទៅធ្វើទាហាន

ខៈ ចាស៎ ទៅធ្វើទាហាន

កៈ ចុះសម្រាប់ដូចជាកូនរបស់លោកយាយគាត់ធ្វើអីវិញដែរ?

ខៈ ចាស៎?

កៈ កូនរបស់លោកយាយគាត់ធ្វើអី?

ខៈ មិនធ្វើអីទេ ធ្វើស្រែ...ធ្វើស្រែអត់ទាន់បានទេ កាលហ្នឹងនៅតូចៗ ចូលសហករណ៍ហើយ

កៈ បាទ ល្អ... អុំ! ចុះសម្រាប់នៅពេលដែលដូចជាជំនាន់ហ្នឹងដល់ពេលចូល ប៉ុល ពត បាន១ឆ្នាំ២ឆ្នាំ គេអោយលោកយាយធ្វើអីគេវិញទៅ?

ខៈ ធ្វើ...នេះ...ធ្វើ...យើងធ្វើស្រែហ្នឹង គេប្រើយើងធ្វើស្រែ

កៈ ធ្វើស្រែអីគេមែន?

ខៈ ធ្វើស្រែសុទ្ធតែម្តង ធ្វើស្ទូង ដក កាប់ ជីក លើកភ្លឺស្រែ

កៈ អុំ! ចុះប្តីលោកយាយគេអោយទៅនៅ...ទៅធ្វើកងទ័ព ធ្វើទាហាន

ខៈ ចាស៎ ប្តីនៅធ្វើទាហាន

កៈ ប៉ុន្តែកាលនៅជាមួយគ្នាឬអត់ទេ?...

ខៈ អត់ទេ បែកគ្នារហូត មកលេងហ្នឹង ថាបានតែកូនមួយ ប្រុសចុងក្រោយហ្នឹង «សើច»

កៈ ចុះសម្រាប់...អញ្ចឹងមានន័យថាជំនាន់ប៉ុលពតរហូតដល់ឥឡូវហ្នឹងលោកយាយគឺធ្វើ...

ខៈ ធ្វើស្រែរហូត

កៈ ធ្វើស្រែរហូត

ខៈ ចាស៎ ដល់ឥឡូវហ្នឹង

កៈ អុំ រហូតដល់ឥឡូវ។ ដាច់ប៉ុលពតលោកយាយក៏នៅតែធ្វើស្រែ

ខៈ ចាស៎ នៅធ្វើស្រែដែរ

កៈ ចុះនៅពេលដែល... ពេលហ្នឹងកូនលោកយាយបានអាយុប៉ុន្មានឆ្នាំដែរ?

ខៈ អាយុមើល...មើលឆ្នាំ'៧៣ខ្ញុំកើតកូនមួយណ៎ះ ហើយ...មែនទេប៉ែត...ប៉ែតបី!

កៈ អូ '៨៣យាយមានកូនមួយ

ខៈ អត់ទេ ការ

កៈ អូ៎! ការកូនមួយ

ខៈ ចាស៎ ចាស៎ កូនបានមួយ ហើយ '៩២ '៩៣ រហូតហ្នឹង នៃ '៨២ '៨៣ហ្នឹង។ រហូត...

កៈ ចុះសម្រាប់នៅពេលដែល... ចុះមានន័យថាជំនាន់ប៉ុលពតហ្នឹង ដូចជាលោកយាយអត់មានគេភៀសខ្លួនអោយទៅណានោះទេ។

ខៈ ទៅជម្លាសហើយ។ គេជម្លាសខ្ញុំមកនេះ កាល '៧៥ គេជម្លាសខ្ញុំមកនេះ មកនៅស្វាយបន្ទាលនេះ ពិបាកណាស់ មកនៅហ្នឹង ខ្ញុំស៊ីតែ...មើមព្រលឹត ហើយរើសខ្យងមកតិចតួចទៅទាញ ត្រកួន ទៅបោចត្រកួនហ្នឹង គេថាស្ទូស្រែប្រាំងណ៎ះ បោចត្រកួនមក អញ្ចឹងខ្ញុំរើសខ្យងស៊ី ខ្ញុំរស់តែខ្យង រស់តែព្រលឹត រស់តែផ្លែអំពិល ហើយគេបបរ គេលាយដំឡូង គេស្ងោរពីល្ងាច ពីរបីខ្ទះ ព្រឹកឡើងគេដាក់អង្ករហើយគេដាក់ដំឡូងនោះច្របល់គ្នាដោយអញ្ចឹងខ្ញុំហូបអត់បានទេ ហើយតែពីរបីវែកទេ! ខ្ញុំពិបាកណាស់ ខ្ញុំវេទនាណាស់ ហើយកូនខ្ញុំនៅតែស្បែកហើយឆ្អឹង ហើយរូបខ្ញុំអញ្ចឹងដែរ ហើយខ្ញុំទៅធ្វើការអោយគេធ្ងន់ណាស់ គេអោយខ្ញុំចាក់អានេះ... គល់រាំងដូចសំណាបអញ្ចឹង ដូចកូនឈើគេដាំដុះច្រូតច្រើនអញ្ចឹង គេអោយខ្ញុំទៅចាក់ឫសរាំងហ្នឹងដើម្បីធ្វើអូរទៅណា...ធ្វើអូរ អូរ សម្រាប់បាចទឹកចូលស្រែ

កៈ បាទ បាទ

ខៈ ហ្នឹងហើយ

កៈ ចុះអញ្ចឹងគេអោយយើងធ្វើតែមួយនេះ ធ្វើតែអញ្ចឹង

ខៈ ធ្វើអញ្ចឹងហើយទៅច្រូត...ទៅច្រូតទៀត ច្រូតហើយកាត់ព្រៃរាំងហ្នឹងទៀត។ ខ្ញុំពិបាកណាស់ ខ្ញុំវេទនាណាស់នៅស្រុកស្វាយផ្ទាហ្នឹង នៅ... គេហៅកើតព្រែកតូចហ្នឹង

កៈ បាទ អញ្ចឹងមានន័យថារបបអាហារយើងគេអោយយើងធ្វើអញ្ចឹងជារៀងរាល់ថ្ងៃ

ខៈ ធ្វើអញ្ចឹងរាល់ថ្ងៃ ព្រោះខ្ញុំគេដាក់កងពិសេស ជាមួយមម៉ាយកងពិសេស ចាស៎ គ្នាខ្ញុំ៥០នាក់

កៈ ប៉ុន្តែ... អញ្ចឹងយើងនៅអត់មានពេលទំនេរមែនទេ?

ខៈ អត់មានទំនេរទេ! យប់ដល់ផ្ទះ ព្រលឹមឡើងម៉ោង៣ចេញទៅ

កៈ អូ៎ ប៉ុន្តែគេអោយយើងសម្រាកទេអញ្ចឹង?

ខៈ អត់... សម្រាកតែម៉ាភ្លែតហ្នឹង តែយើងហូបបបរ មួយគ្រូកពីរគ្រូកនោះ ទៅទៀត។

កៈ

ចុះនៅពេលដែលលោកយាយទៅពីហ្នឹងគេមានដូចជម្លៀសអោយលោកយាយមានទៅណាអីទៀតអត់?

ខ៖ អត់ទេ ខ្ញុំនៅតែស្វាយបន្ទាលទាល់តែវៀតណាមចូល។

ក៖ អ៊ំ មានន័យថានៅហ្នឹងរហូតហួងហើយយើងធ្វើការងារអញ្ចឹងរហូត

ខ៖ ចាស៎ នៅហ្នឹងរហូត ចាស់ខ្ញុំធ្វើរហូត ខ្ញុំបោកស្រូវខ្ញុំបោកហើយយកអាក្តាប់ស្រូវហ្នឹង គេអោយក្រង គេអោយក្រងធ្វើជាប្រក់ផ្ទះ

ក៖ បាទ បាទ ល្អ
ចុះនៅពេលដែលដូចជាលោកយាយរហូតទាល់តែវៀតណាមគេមករំដោះខ្មែរយើងហើយ ពេលហ្នឹងលោកយាយគេជម្លៀសទៅណាទៀត?

ខ៖ នែ៎ វៀតណាមប្រាប់ថាអោយទៅស្រុកស្រែយើងវិញ ស្រុកណាទៅស្រុកហ្នឹងវិញខេត្តណាទៅខេត្តហ្នឹងវិញ ខ្ញុំក៏ទៅរៀបចំណំ៖ ទៅៗមានអីទេ មានតែខ្ញុំទៅរត់ទៅកេប... រត់ទៅអ្នកច្រូតស្រូវហើយខ្ញុំយកមកបុក កិនអង្ករហ្នឹងបានមួយប៉ាតេ កាលនោះគេហៅប៉ាតេ! អាប៉ាវថ្មីហ្នឹង ប៉ាវចងមាត់ហ្នឹង ហើយខ្ញុំក៏រុញរទេះខ្ញុំ... ឪខ្ញុំមើលគាត់ឈឺ នៅដាក់រទេះរុញ ហើយខ្ញុំ កូនខ្ញុំមួយនៅអឹម
(ប៉ៅដោះ) ពីរហ្នឹងដើរយំដើរបណ្តើរៗព្រោះគ្មានមនុស្សប្រុស ខ្ញុំកម្សត់ណាស់ ខ្ញុំដើរទៅស្រុកវិញ ខ្ញុំវេទនាណាស់ ទៅគាស់ដំឡូងព្រៃហ្នឹងយកមកស្ងោរហួប បបរហួប ហើយខ្ញុំក៏ស៊ីគល់ចេក ស៊ីគល់ល្ហុង ហើយដល់ពេលធ្លាក់តិចមកព្រលឹតអញ្ចឹងអីវាដុះទៅ ត្រកួនដុះ បបរត្រកួន ស្រុះត្រកួនហ្នឹង ហើយសៅម៉ៅហ្នឹងបេះយកមកស្រុះស៊ី អើយកម្សតណាស់ខ្ញុំ។

ក៖ អញ្ចឹងនៅពេលហ្នឹងលោកយាយដូចជាមាន...ដូចជាធ្វើការរកស៊ីអីឬក៏អីហ្នឹង?

ខ៖ ខ្ញុំមករកស៊ីហ្នឹងដល់ហើយខ្ញុំទៅសុំហ្នឹង...ទៅរកអាស្លឹកឈើស្លឹកព្រៃលែងបានហ្នឹង ខ្ញុំក៏មកសុំទាននៅស្រុកស្អាងនេះ...គេហៅ...អានេះ...ស្រុកស្អី?...ស្រុកស្អីទេ! នៅស្រុក...នៅខេត្តព្រៃវែង ស្រុកមេសាង។ ខ្ញុំដើរសុំទានគេហ្នឹងយកមកបាន គេអោយមុនដំបូង គេអោយអញ្ចឹងក្រែលណំ៖ តែបានបុកអង្ករបានជាពីរល្អីបីល្អីយកមកផ្ទះ ហើយទៅហើយទៅទៀតសុំទានទៀត ដល់សុំមកបានទៀតទៅ ដោយយូរៗគេលែងអោយយើងច្រើន គេអោយមួយក្តាប់ៗអោយយើង ហើយខ្ញុំហើយពីហ្នឹង ខ្ញុំក៏ទៅរកស៊ីកាប់ឈើទៀត កាប់ឈើវៀតណាម កាប់ឈើហ្នឹងដើម្បីយកមកលក់ កាប់ជាអុសក្រណាត់ៗលក់ទៅផ្សារ ចាស៎។
លក់យកមកចិញ្ចឹមកូនចិញ្ចឹម ម៉ែ។កូនខ្ញុំត្បិតខ្ញុំចិញ្ចឹមមើល ប្អូនខ្ញុំ៥នាក់ហ្នឹងហើយម៉ែខ្ញុំមួយទៀត ហើយខ្ញុំ៩នាក់ម៉ែកូនទៀត

ក៖ ទាំងអស់ជាងដប់នាក់បាត់ហើយ

ខ៖ ចាស៎ ខ្ញុំរកស៊ីចិញ្ចឹម ប្អូនអ្នកទៅលក់ខ្ញុំអ្នកទៅលី ឈើធំៗវែងៗអូសតាមទឹក ទៅហែលទឹកអូសតាមទឹក

ក៖ ដូចជាយើងធ្វើរបៀបម៉េចទៅលោកយាយ? ដូចជាគេអោយយើងដើម្បីទៅកាប់យកមកឬក៏យើង...

ខ៖ ទៅលួចគេហ្នឹង!

ក៖ អូ ទៅលួចគេ

ខ៖ ទៅលួច! ចាស៎ ទាំងអស់គ្នាហ្នឹង! ទៅលួចគេយកមកដើម្បីកាប់យកទៅលក់ទិញអង្ករស៊ី

ហើយមានទិញអង្ករហើយទិញអង្ករពោតហ្នឹងហើយស្ងួគ្រាប់ពោតធំៗ
ហើយក៏បានរកដល់ខែយើងធ្លាក់ទឹកហ្នឹងទៅហើយយើងទៅរកសុំទានគេទៀតយកមកធ្វើពូជ
ធ្វើពូជដើម្បីនឹងស្ទូដកហ្នឹង ហើយកម្សត់ណាស់ពីរបីឆ្នាំបានពូជស្រូវហ្នឹងសុទ្ធ យើង
ធ្វើបានច្រើនទៅបាន ស៊ីបរិបូរ

កៈ ចុះសម្រាប់អ្នកដែលទៅជាមួយលោកយាយធ្លាប់មាន... ដូចជាមានបញ្ហាអីសម្រាប់មួយជនជាតិ
វៀតណាមអីគេ?

ខៈ មានទេ! មានតែវៀតណាមគេដេញយើង កុំអោយយើងទៅលួចឈើគេ

កៈ ប៉ុន្តែគេអត់មានចង់វាយយើងអីទេ?

ខៈ អត់ទាន់ទេ គេយកតែកាំបិតពូថៅ គេយកកាំបិតពូថៅ គេ កុំបាន ព្រៃវៀតណាមកុំ
ងាប់អស់ហើយខ្មែរ ចាស៎ រកស៊ីលួចគេយកទៅធ្វើឧសចងជាដុំៗបីបី ណាំះ
ដឹកវាទៅលក់អោយជំភូ ទូលខ្ញុំទូលទាំងពីឈើទូលទាំងពីអីយកទៅលក់អោយគេ
អ្នកទិញគេមកគេរកស៊ីទិញគេលក់ដូរ គេទិញយកធ្វើជាខ្ទមជាផ្ទះអីគេ
ចាស៎ខ្ញុំពពីស្រុកខ្ញុំទៅថ្ងៃហ្នឹងទៅកាប់ថ្ងៃមកវិញលួសអីអោយស្អាតប៉ុនៗហ្នឹង
លក់ដើមបានតែពីររៀលទេ! តែជំនាន់កាក់យើងចេញថ្មីហ្នឹង ហើយមួយកាក់ពីរកាក់ហ្នឹង
បានតែ២រៀល៣រៀលអោយអររខេបរខុប (មានន័យថាអរខ្លាំង)
ហើយលីហ្នឹងមួយយប់ហើយថ្ងៃហ្នឹងបានដល់ទៅផ្ទះវិញ។

កៈ ចុះសម្រាប់រហូតដល់ឆ្នាំណាដែលកូនលោកយាយដូចជាបានការ?

ខៈ បានការ...ឆ្នាំ '៨៦ '៨៧ហ្នឹង

កៈ ចុះកូនលោកយាយនៅពេលដែលគាត់ការគាត់ធ្វើអីគេវិញទៅ?

ខៈ ធ្វើស្រែដែរដូចគ្នាហ្នឹង

កៈ អូ ធ្វើស្រែ ចុះប្តីគាត់អី...?

ខៈ ធ្វើស្រែដូចគ្នាជាមួយគ្នា ចាស៎ ជាមួយគ្នា ចាស៎

កៈ ចុះកូនបន្ទាប់ៗ?...

ខៈ អញ្ចឹងដែរ! ធ្វើតែស្រែហ្នឹង រៀនសូត្របានតិចតួចៗ

កៈ ចុះនៅពេលដែលលោកយាយ... អញ្ចឹងលោកយាយធ្វើហ្នឹងរហូតដល់ឆ្នាំណាដែលបាន
លោកយាយឈប់ធ្វើវា?

ខៈ ធ្វើស្រែ...?

កៈ អត់ទេ ធ្វើ...ដូចជាលីឧសលីអី

ខៈ អុំ ទើបបានឈប់ទេ! ទើបបានឈប់អង្កាល '៩២ '៩៣នោះទេ! ឈប់ណាំះ!
ដល់យើងធ្វើស្រូវបាន...កៅតិចៗតិចៗនិងឈប់

កៈ ចុះនៅពេលលោកយាយឈប់អញ្ចឹងលោកយាយធ្វើអីគេទៅ?

ខ៖ ធ្វើស្រែទៀត!

ក៖ ធ្វើស្រែទៀត

ខ៖ ចាស៎ មិនចោលទេស្រែ នៅស្រែធ្វើស្រែ

ក៖ ដូចជាលោកយាយមានដីស្រែច្រើនមែនទេ?

ខ៖ ខ្ញុំចែកអោយកូនអស់ហើយ! ដីស្រែហ្នឹង ចែកអោយកូនដល់២០ៗអារម្នាក់ ប្ដីគេចែកដែរ។

ក៖ នៅពេលដែលយើងដាច់ប៉ុលពតភ្លាម
ស្រែគេចែកអោយយើងឬក៏យើងចាប់យកស្រែដោយខ្លួនឯង?

ខ៖ ចាប់យកខ្លួនឯង ប៉ុនដល់ហើយគេ... ប៉ុនហ្នឹងគេចែកឆ្នាំណាទេខ្ញុំក៏ភ្លេចដែរហ្នឹង ខ្ញុំមិនបានគិត
ដល់គេចែកទៅវាក៏បានតិចជាងអារបស់យើង របស់យើងពីលើកមុន កេរ្តិ៍អាករយើងហ្នឹងហើយ

ក៖ វាច្រើនជាងហ្នឹង...

ខ៖ ចាស៎ ពីមុនច្រើនណាស់ធ្វើមិនអស់ទេ ប្រាំប្រាំមួយហិចតាដល់បានតែមួយហិចតាកន្លះ!
យកគេចែក គេចែកតាមគ្រួសារ គេចែកតាមមនុស្ស... ៥នាក់អញ្ចឹងបានហិចតាកន្លះអញ្ចឹងទៅ។

ក៖ ចុះអញ្ចឹងសម្រាប់យើង
យើងធ្វើស្រែហើយយើង...ដូចជាយើងបានស្រូវបាយយកទៅលក់នៅណាទៅ?

ខ៖ លក់ឲ្យគេ... កាលហ្នឹងគេធ្វើ...អា ឥឡូវហ្នឹងលក់អោយយួនហ្នឹង
គេយួនវាដឹកអីវាចង់ទិញអង្ករមួយតោនយើងកិនស៊ីមិនអស់ទេទៅលក់ និយាយត្រង់ណ៎ះ

ក៖ បាទ អញ្ចឹងនៅពេលដែលយើង...ដូចជាយើងកិនលក់អញ្ចឹងយើងទៅលក់នៅ...
គេមកទិញដល់ផ្ទះយើងឬក៏យើងដើរលក់តាមផ្លូវ?

ខ៖ គេមកទិញដល់ផ្ទះ

ក៖ គេមកទិញដល់ផ្ទះ អញ្ចឹងមានន័យថាការចំណាយរយៈពេលប៉ុន្មានទៅដើម្បីអាចធ្វើវាបាន?
ដូចជា១ប៉េ២ប៉េអី?

ខ៖ យើងកិនមួយតោនទៅ...បើយើងបានច្រើនយើងហាលច្រើនកិន១០ប៉ាវ១០ថ្ងៃហើយទៅហើយ!

ក៖ បាទ ល្អ អញ្ចឹងរហូត បន្ទាប់ពីធ្វើស្រែរហូតមកដល់ឥឡូវគឺលោកយាយធ្វើអញ្ចឹងរហូត

ខ៖ ធ្វើអញ្ចឹងរហូត ចាស៎។

ក៖ ចុះសម្រាប់កូនចៅលោកយាយ?

ខ៖ កូនចៅគេចេញរបស់គេ ហើយដូចដែលខ្ញុំធ្វើស្រែអញ្ចឹង ខ្ញុំធ្វើស្រែកូនខ្ញុំហ្នឹង នៅផ្ទះហ្នឹង
នៃកូនចៅគេមកជួយ ហើយជួលគេកាត់កូនខ្ញុំពីហ្នឹង ទៅអោយជួលអាត្រាក់ (ត្រាក់ទ័រ) គេភ្ជួរ គេជួល
ចាស៎ ខ្ញុំដូចថាគ្រាន់តែជំហរទេ ច្រូតអញ្ចឹងដែរ ដូចថាលើកផ្ទៃលើកអីប្រមូលផលកូននៅហ្នឹងជួយ។

កៈ បាទ ល្អ ចុះរហូតម្តល់ពេលហ្នឹង ពេលណាដែលកូនលោកយាយដូចជាបំបែកគ្នាដើម្បីចេញពីលោកយាយ? ពួកគាត់...

ខៈ ខ្ញុំនៅជាមួយកូនហ្នឹង!

កៈ អត់ទេ ចង់និយាយថាកូនលោកយាយមាន៣នាក់

ខៈ ចង់មានន័យកូនកាលមុនទេ? អូ គេការហើយគេចេញ ការហើយគេទៅផ្ទះខាងព័ន្ធគេខាងប្តីគេ។ ខ្ញុំនៅជាមួយកូនសព្វថ្ងៃហ្នឹង

កៈ ប៉ុន្តែសម្រាប់គាត់គាត់ធ្វើអីគេវិញទៅ?នៅ...

ខៈ ធ្វើស្រែដូចគ្នា

កៈ ធ្វើស្រែប៉ុន្តែនៅភូមិផ្សេង?

ខៈ ចាស់ភូមិផ្សេង ផ្ទះគេផ្សេង...

កៈ ចុះសម្រាប់កូនលោកយាយមួយទៀតហ្នឹង? មួយទៀតដែល...

ខៈ ដូចគ្នាអញ្ចឹង។

កៈ អញ្ចឹងជីវភាពទាំងប្តីទាំងប្រពន្ធគាត់គឺធ្វើស្រែទាំងអស់គ្នា?

ខៈ ធ្វើស្រែ

កៈ ចុះសម្រាប់កូនលោកយាយនៅជាមួយ?...គាត់ធ្វើស្រែដែរ?

ខៈ គាត់មកហ្នឹង ធ្វើស្រែដែរ ខ្ញុំនៅហ្នឹងខ្ញុំជំហរធ្វើនៅនោះ ចាស់

កៈ អញ្ចឹងឆ្នាំណាដែលកូនលោកយាយមកនៅភ្នំពេញហើយ?

ខៈ កូនខ្ញុំនៅហ្នឹងយូរគ្រែលហើយឡើយជាង១០ឆ្នាំហើយ មុនដំបូងនៅតែកូនប្រសាទេ ដោយនៅយូរៗឃើញកូនពិបាក គេទៅរៀនឆ្ងាយពេក ចៅៗកូន...យកកូនមកនៅហ្នឹង រៀនសូត្រនៅហ្នឹង

កៈ ចុះគាត់មកនៅហ្នឹង គាត់ដូចជា...គាត់នៅផ្ទះជួលឬក៏...?

ខៈ គាត់នៅផ្ទះជួល ចាស់សព្វថ្ងៃហ្នឹង

សៈចុះសម្រាប់គាត់ដូចជាមានបញ្ហាអ្វីសម្រាប់ពួកគាត់នៅក្នុងជីវិតពួកគាត់ទាំងកូនៗលោកយាយហើយនិងសម្រាប់លោកយាយ?

ខៈ ខ្ញុំមិនដែលមានបញ្ហាជាមួយកូនជាមួយចៅអីទេ!

កៈ អត់ទេ ចង់និយាយថាលោកយាយដែលមានបញ្ហាអីសម្រាប់លោកយាយចងចាំអីពីមុន សម្រាប់បញ្ហា
អីកើតឡើងសម្រាប់ក្នុងជីវិតលោកយាយដូចជាលោកយាយមានចាំថាលោកយាយមានបញ្ហាអីកើត

ឡើង មិនមែនកូនចៅប៉ុន្តែសម្រាប់អ្វីមួយដែលលោកយាយចាំក្នុងខ្លួនឯង ក្នុងជីវិតខ្លួនឯង?

ខះ ជីវិតខ្ញុំវាពិបាកណាស់ហើយ! ឥឡូវទើបបានធូរជារកូនចៅអីគេ ការចេញអស់ហ្នឹងធូរបន្តិច។ ខ្ញុំវេទនាណាស់គ្រូអើយ

កះ ចុះសម្រាប់សព្វថ្ងៃហ្នឹងលោកយាយនៅម៉ាននាក់ដែរ? នៅស្រុក?

ខះ ខ្ញុំនៅស្រុកម្នាក់ឯង ហើយចៅៗអីទៅ គេមកដេកមកនៅទៅ... ដេកពេលល្ងាចអីទៅ... ជូនណាខ្ញុំទៅដេកផ្ទះកូនទៅ ចាស់

កះ បាទ ហើយទៅ...លោកយាយនៅហ្នឹង លោកយាយមានស្រែចម្ការមានអីដែរឬក៏មាន...?

ខះ ខ្ញុំធ្វើស្រែកូន

កះ ធ្វើស្រែកូន

ខះ ចាស់ ស្រែខ្ញុំខ្ញុំចែកអោយកូនអស់ហើយ

កះ បាទ ល្អ!

ខះ សព្វថ្ងៃខ្ញុំធ្វើស្រែវ៉យយើងណ៎ា ចាស់!

កះ បាទ ចុះសម្រាប់ដូចជារាល់ថ្ងៃលោកយាយនៅស្រុក លោកយាយដូចជារបបអាហារលោកយាយ លោកយាយធ្វើម៉េច? ដូចជាលោកយាយធ្វើដោយខ្លួនឯងឬក៏មាននរណា...?

ខះ ធ្វើខ្លួនឯង! ជូនណាកូនហៅទៅហូបទៅ ជូនណាយើងដាំម្ហូបរបស់យើង ចាស់។

កះ អ៎ូ ប៉ុន្តែផ្ទះពួកគាត់នៅជិតៗគ្នាដែរឬក៏...?

ខះ នៅឆ្ងាយៗដែរ ប្រហែលមួយគីឡូ មួយគីឡូកន្លះដីដែរ ចាស់។

កះ ប៉ុន្តែកូនលោកយាយពួកគាត់មកលេងលោកយាយរៀងរាល់សប្ដាហ៍ដែរឬក៏...?

ខះ ចាស់ គេមកលេង ពីរបីថ្ងៃមក ពីរបីថ្ងៃយើងទៅអញ្ចឹង ចាស់។

កះ អ៎ូ បាទ ចុះសម្រាប់កូនចៅលោកយាយធ្វើស្រែដែរនៅហ្នឹង។

ខះ ធ្វើស្រែទាំងអស់គ្នា។

កះ ប៉ុន្តែនៅភូមិណាវិញទៅលោកយាយ?

ខះ នៅភូមិព្រែកតាអីដូចគ្នា

កះ ចុះសម្រាប់ឥឡូវហ្នឹងដូចជាលោកយាយមានកូនចៅទាំងអស់មកម៉ានលោកយាយ?

ខះ ចៅខ្ញុំ... ចៅខ្ញុំមើល... ពីរបីប្រាំ...ហើយនេះប្រាំទៀត...ដប់...ចៅទួតពីរទៀត ដប់ពីរ...មានដប់ពីរនាក់ចៅ

កៈ អូ៎ ១២នាក់! ច្រើនដែរ!

ខៈ គេមិនយកច្រើន យកតែពីរបី «សើច»

កៈ អូ៎ ចុះសម្រាប់លោកយាយ លោកយាយគិតថានឹងទៅនៅជាមួយកូនចៅ ឬក៏លោកយាយ
ដូចជានៅតែឯង?

ខៈ ខ្ញុំនៅជាមួយកូនចៅ ពេលខ្ញុំទៅស្រុកខ្ញុំទៅទៅ ពេលខ្ញុំមកខ្ញុំមកហ្នឹង ចាស៎។

កៈ អូ៎ ប៉ុន្តែដូចជា...សម្រាប់លោកយាយ លោកយាយនៅតែឯងអញ្ចឹងលោកយាយមាន
អារម្មណ៍ថាឯកោឬក៏អីដែរ?

ខៈ អារម្មណ៍ឯកោវាធម្មតាទេណា ខ្ញុំនឹកដល់កូនចៅខ្លាចរកស៊ីទៅក្រ នឹកអាណិតកូនអាណិតចៅណ៎ះ!

កៈ អូ៎ បាទ! ចុះសម្រាប់មួយទៀតខ្ញុំចង់សួរលោកយាយធ្លាប់គិតថានឹងរៀបចំអីសម្រាប់
ពួកគាត់នៅពេលដែលកូនចៅលោកយាយធំៗទៅទៀត តៗលោកយាយធ្លាប់គិតថាវាចង់ធ្វើអីទៀត
សម្រាប់ពួកគាត់ទៀតទេ?

ខៈ ខ្ញុំចង់អោយកូនចៅហ្នឹងរៀនសូត្រអោយបានចេះដឹងជ្រៅជ្រះ ចាស៎។

កៈ បាទចុះមួយទៀតសម្រាប់លោកយាយនៅផ្ទះហ្នឹង...
នៅផ្ទះលោកយាយគឺលោកយាយនៅផ្ទះដោយខ្លួនឯងមែនទេ?

ខៈ ខ្ញុំនៅផ្ទះខ្លួនឯង

កៈ នៅផ្ទះខ្លួនឯង...

ខៈ ចាស៎!

កៈ ចុះប៉ុន្មានសប្តាហ៍ប៉ុន្មានអីលោកយាយមកលេងភ្នំពេញមកលេងកូនចៅលោកយាយម្តង

ខៈ ទៅមួយខែម្តង ជួនណា២ខែអីមក កាលណាយើងដូចថាមាននៅធ្វើស្រែខ្ញុំទៅធ្វើស្រែ ខ្ញុំមិនធ្វើទេ
កូនខ្ញុំអ្នកធ្វើអីគេអ្នកផ្តល់លុយទៅអោយខ្ញុំមើលជូនថ្ងៃណាព្រោះថ្ងៃណាអញ្ចឹង

កៈ បាទ ចុះនៅពេលដែលលោកយាយធ្វើអញ្ចឹងរាល់ថ្ងៃ សម្រាប់ដូចជា...
លោកយាយមានជីវភាពជា..សាមញ្ញរាល់ថ្ងៃមែនទេលោកយាយ?

ខៈ មានសាមញ្ញនៅម្នាក់ឯង ឯកោ «សើច» ចង់រកធ្វើអីធ្វើ ចង់...យើងចង់សម្រាក សម្រាក...
ចាស៎ដូចថាដេកទម្រេកលេងថ្ងៃអញ្ចឹង។

កៈ បាទ ហើយខ្ញុំមានសំណួរមួយទៀត លោកយាយបានជឿលើព្រះគម្ពីរព្រះវិហារមែនទេ?

ខៈ ខ្ញុំជឿចាស៎!

កៈ ហេតុអ្វីលោកយាយបានសម្រេចចិត្តថា...?

ខៈ ខ្ញុំបានត្រង់ជឿថាទ្រង់បង្កើតទឹកដីណ៎ះ ព្រៃប្រឹក្សា សត្វទៀត...សត្វ...គ្រប់សត្វប្រភេទទាំងអស់។

ក៖ បាទ!

ខ៖ ចាស៎! ហើយមនុស្សលោកយើងហ្នឹង ចាស៎ខ្ញុំយល់។

ស៖ បាទប៉ុន្តែមាន...ដូចជាមានចំណុចណាដែលលោកយាយជឿថាហេតុអ្វីបានលោកយាយគួរតែទៅព្រះវិហារ?ហើយដូចជាលោកយាយជឿថាព្រះជាព្រះពិត? ហេតុអ្វី...
មានចំណុចណាអីគេដែលសម្គាល់
អោយលោកយាយអោយលោកយាយអាចជឿទៅលើចំណុចមួយហ្នឹងបានលោកយាយ?

ខ៖ ខ្ញុំសម្គាល់ចាស៎ សម្គាល់អោយតែយើងធ្វើល្អ ទ្រង់តាមថែរក្សាយើង ហើយខ្ញុំមិនដែលទៅរអ៊ូរ រំខានអីអ្នកណាខ្ញុំជឿថាត្រង់ធ្វើល្អ ទ្រង់ប្រៀនប្រដៅមកអោយយើងធ្វើល្អ កុំឈ្នានីសគេ
កូនយើងដូចកូនចៅយើងចេះស្រលាញ់កូនស្រលលាញ់ចៅ ជួយអប់រំកូនចៅ ខ្ញុំជឿត្រង់ប៉ុណ្ណឹង។

ក៖ បាទ អញ្ចឹងប្រហែលជាខ្ញុំមានសំណួរខ្លះៗតែប៉ុណ្ណឹងសម្រាប់លោកយាយ
អញ្ចឹងមួយទៀតខ្ញុំចង់សួរ
លោកយាយថាអញ្ចឹងលោកយាយធ្លាប់គិតថាប្រវត្តិលោកយាយ...លោកយាយធ្លាប់គិតថានឹងទុកអោយ
កូនចៅបន្តជាជំនាន់ក្រោយអោយយល់ដឹងឬក៏ជាអីកើតឡើងសម្រាប់លោកយាយទេ?

ខ៖ ចាស៎ខ្ញុំទុកជាបន្តតៗទៅទៀតកូនចៅអោយយកគំរុខ្ញុំហើយស្តាប់ព្រះ ចាស៎ដោយសារខ្ញុំជឿជាក់

ក៖ បាទ ដោយសារយើងនឹងធ្វើជាគំរូអីហ្នឹងហើយគំរូរបស់លោកយាយ
របស់លោកយាយទុកតដល់កូនចៅ លោកយាយ
ហើយទៅសម្រាប់សាលាយើងសម្រាប់ដូចជាយើងយកប្រវត្តិ របស់លោកយាយដើម្បីអោយជាសម្គាល់ទុកអោយកូនចៅរបស់យាយដឹងថាលោកយាយមានហេតុការអីកើតឡើងខ្លះចំពោះជីវិតរបស់លោកយាយកាលពីលោកយាយនៅតូចរហូតដល់លោកយាយ...ដល់ឥឡូវ
បាទអញ្ចឹងប្រហែលជាខ្ញុំមាន សំណួរតែប៉ុណ្ណឹងសម្រាប់លោកយាយ
ខ្ញុំអស់ហើយអរគុណច្រើនលោកយាយបានផ្តល់ឱកាស ដូចជាប្រាប់
ដូចជាប្រវត្តិរបស់លោកយាយមកខ្ញុំ។